**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១៤០០ ព.ណ.ន.ស.ពកព

ថ្ងៃចន្ទ ១១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មេសា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា **«ពិព័រណ៍អាហារអន្តរជាតិហ្វីលីពីន និងការផ្លាស់ប្តូរដំណោះស្រាយប្រកបដោយចីរភាព លើកទី១៩»** នឹងប្រព្រឹត្តទៅពីថ្ងៃទី២១-២៣ ខែឧសភា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក (World Trade Center) នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។ ព្រឹត្តិការណ៍ពិព័រណ៍នេះ គឺជាវេទិកាសកលមួយសម្រាប់ក្រុមហ៊ុនម្ហូបអាហារ និងភេសជ្ជៈ ក្នុងការផ្សព្វផ្សាយផលិតផលរបស់ខ្លួន និងពង្រឹងទំនាក់ទំនងជាមួយអ្នកបញ្ជាទិញអន្តរជាតិ តាមរយៈការដាក់តាំងបង្ហាញផលិតផល រួមមាន នំដុត ភេសជ្ជៈ បន្លែនិងផ្លែឈើ ប្រភេទសាច់ គ្រឿងសមុទ្រ ផលិតផលធ្វើពីរុក្ខជាតិ នំកញ្ចប់ និងសេវាកម្មពាក់ព័ន្ធ។ ពិព័រណ៍ខាងលើ ក៏នឹងផ្តល់នូវកាលានុវត្តភាពសម្រាប់ក្រុមហ៊ុន/សហគ្រាសកម្ពុជា ក្នុងការចាប់ដៃគូជាមួយអ្នកបញ្ជាទិញអន្តរជាតិ អ្នកនាំចូល និងអ្នកលក់បន្ត ក្នុងវិស័យកសិ-ចំណីអាហារ និងផ្នែកផ្សេងៗទៀតនៃធុរកិច្ចកសិកម្ម។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួល សូមអញ្ជើញ លោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍ខាងលើក្នុងនាមជាអ្នកបញ្ជាទិញ សូមធ្វើការទំនាក់ទំនងមកនាយកដ្ឋានជំរុញពាណិជ្ជកម្ម និងកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានគោលនយោបាយ និងជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ +៨៥៥ ៧៧ ៣៦១ ៨៣៦ / +៨៥៥ ៨៧ ៧៥៥ ៥៥១ ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម **១២៦៦** ឬអ៊ីម៉ែល៖ oun.veasna@moc.gov.kh / tong.rita@moc.gov.kh។

សម្រាប់ចុះឈ្មោះ

https://go.gov.kh/moc/mznasw

GO.gov.kh

**សូមអរគុណ!**

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N°1400 MOC.D/TPEA

Phnom Penh, 27 April 2026

# ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all traders and the public that **"The Nineteen International Food Exhibition (IFEX) Philippines and Sustainability Solutions Exchange (SSX)"** will be held from 21-23 May 2026 at the World Trade Center in Manila, Philippines. This international event serves as a global platform for food and beverage companies to promote their products and strengthen connections with international buyers. The exhibition will showcase a wide range of products, including bakery goods, beverages, fruits and vegetables, meat, poultry, seafood, plant-based products, snacks and allied trade services and offers valuable opportunities for Cambodian enterprises to explore partnerships in agri-food and other agri-business sectors.

In this regard, the Ministry of Commerce, as a facilitator, would like to cordially invite Cambodian traders and the public who are interested as a buyer in the aforementioned event to kindly register with the Department of Trade Promotion and Exhibition Affairs, General Department of Trade Policy and Promotion, Ministry of Commerce at Lot No. 19-61, Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, or officials in charge via:

Tel: +855 77 361 836 / +855 87 755 551

MOC Call Center: 1266

E-mail: oun.veasna@moc.gov.kh / tong.rita@moc.gov.kh.

For Registration

https://go.gov.kh/moc/mznasw

GO.gov.KH

THANK YOU!